ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កំណត់ហេតុ

## កិច្ចប្រជុំពិគ្រោះយោបល់លើកទី២ កម្រិតថ្នាក់ដឹកនាំបច្ចេកទេស នៃប្រទេសបញ្ជូនទាំងបី (កម្ពុជា ឡាវ មីយ៉ាន់ម៉ា) ស្តីពី តួនាទីប្រទេសបញ្ជូន ដើម្បីពង្រឹងកិច្ចការពារពលករទេសន្តរប្រវេសន៍

(ថ្ងៃទី៣០-៣១ ខែតុលា ឆ្នាំ២០១៩)

ថ្ងៃទី១៖ថ្ងៃពុធ បីកើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.ពីរពាន់ប្រាំរយហុកសិបបី ត្រូវនឹងថ្ងៃទីសាមសិប ខែតុលា ឆ្នាំពីរពាន់ដប់ប្រាំបួន វេលាម៉ោង ប្រាំបួន និងសូន្យនាទីព្រឹក នៅសណ្ឋាគារសុខាល័យអង្គរ ទីរួមខេត្តសៀមរាប មានរៀបចំពិធីបើក នៃកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ កម្រិតថ្នាក់ដឹកនាំបច្ចេកទេស នៃប្រទេសបញ្ជូនទាំងបី (កម្ពុជា ឡាវ មីយ៉ាន់ម៉ា) ស្តីពី "តួនាទីប្រទេសបញ្ជូន ដើម្បីពង្រឹងកិច្ចការពារពលករទេសន្តរប្រវេសន៍" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)។

**សមាសភាពចូលរួម៖**

- គណៈប្រតិភូ ប្រទេសមីយ៉ាន់ម៉ា ដឹកនាំដោយ ឯកឧត្តម ឧត្តមសេនីយ៍ឯក **អោង ធូ** (Aung Thu) អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃសហភាពមីយ៉ាន់ម៉ា និងមន្ត្រីបច្ចេកទេស សរុបចំនួន ៥ រូប ។
- គណៈប្រតិភូ ប្រទេសឡាវ ដឹកនាំដោយលោក វរៈសេនីយ៍ឯក បណ្ឌិត **ផេងសាវ៉ាញ់ ធីផាវង្សសៃ** (Pol.Col.Dr. Phengsavanh Thipphavongsay) អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាល និងជាប្រធានលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស ក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋ ប្រជាមានិតឡាវ និងមន្ត្រីបច្ចេកទេស សរុបចំនួន ៥ រូប ។
- តំណាងប្រទេសកម្ពុជា ដឹកនាំដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងមន្ត្រីបច្ចេកទេសអន្តរក្រសួង សរុបចំនួន ១៧ រូប។

ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត និងអង្គការដៃគូជាតិ អន្តរជាតិ សរុបចំនួន ៨២ រូប ស្រី១៩ រូប ។

**កិច្ចចាប់ផ្តើមកម្មវិធី**

លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ពាក់ព័ន្ធនឹងកិច្ចប្រជុំថា៖ នេះជាលើកទី២ហើយ ដែលគណៈប្រតិភូនៃប្រទេសយើងទាំងបីបានជួបជុំគ្នា ដើម្បីពិភាក្សារកដំណោះស្រាយបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋយើង ដែលបាននិងកំពុង ធ្វើទេសន្តរប្រវេសន៍ការងារនៅក្រៅប្រទេស ជាពិសេសក្នុងប្រទេសថៃ ។ កាលពីថ្ងៃទី ២៤ និង២៥ ខែឧសភា ឆ្នាំ២០១៨ ឆ្នាំកន្លងទៅ យើងក៏បានជួបជុំគ្នានៅទីនេះដែរជាកិច្ចប្រជុំលើកទី១ តែជាការចាប់ផ្តើម មិនទាន់មានលទ្ធផលជាផ្លែផ្កានៅឡើយ។

ដូច្នេះក្នុងកិច្ចប្រជុំលើកទី២ ថ្នាក់មន្ត្រីជាន់ខ្ពស់កម្រិតបច្ចេកទេសនេះ យើងនឹងពិភាក្សាដោយបើកចំហរជាលក្ខណៈមិត្តភាព ដើម្បីរកឲ្យឃើញនូវបញ្ហាដែលជាអាទិភាព បទពិសោធន៍ក្នុងការដោះស្រាយ និងគំនិតផ្តួចផ្តើមក្នុងការធ្វើឲ្យប្រសើរឡើងនូវកិច្ចការពារសុវត្ថិភាព ព្រមទាំងសិទ្ធិ និងផលប្រយោជន៍របស់ពលករ និងប្រទេសជាតិផងដែរ ។ **លោកជំទាវ** បានលើកឡើងពីគោលបំណងសំខាន់ នៃកិច្ចប្រជុំគឺៈ

**ទី១**.ស្វែងយល់អំពីស្ថានភាព និងទំនោរនៃទេសន្តរប្រវេសន៍បច្ចុប្បន្ន ដើម្បីរិះរកវិធានការ ក្នុងការលុបបំបាត់ការធ្វើទេសន្តរប្រវេសន៍មិនប្រក្រតី ការជួញដូរមនុស្ស និងរាល់ទម្រង់នៃអំពើកេងប្រវ័ញ្ចក្នុងវដ្តនៃទេសន្តរ ប្រវេសន៍ និងលើកម្ពស់ ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ ។

**ទី២**. កំណត់រកបញ្ហារួម និងផ្លាស់ប្តូរមេរៀនបទពិសោធន៍ល្អៗ ក្នុងការដោះស្រាយបញ្ហាទាំងនោះ តាមរយៈការពង្រឹងកិច្ចសហការក្នុងការឆ្លើយតបទៅនឹងការងារបង្ការទប់ស្កាត់ ការអនុវត្តច្បាប់ និងកិច្ចការពារជនរងគ្រោះនៅក្នុងប្រទេសរៀងៗខ្លួន ក៏ដូចជាក្នុងប្រទេសគោលដៅ ។

មតិចូលរួម និងចំណាប់អារម្មណ៍ក្នុងកិច្ចប្រជុំដោយ **លោកស្រី គ្រីស្ទីន ផាកូ** (Ms.KRISTIN Parco) ប្រធានបេសកកម្មអង្គការអន្តរជាតិទេសន្តរប្រវេសន៍ប្រចាំកម្ពុជា (IOM) គាំទ្រចំពោះការជួបប្រជុំគ្នារវាងប្រទេសជាសមាជិក (កម្ពុជា ឡាវ មីយ៉ាន់ម៉ា)។ លោកស្រី គ្រីស្ទីន បានបញ្ជាក់ថា យើងត្រូវធ្វើការរួមគ្នាដើម្បីធ្វើឲ្យពលករទេសន្តរប្រវេសន៍មានជម្រើសច្បាស់លាស់ និងមិនធ្វើចំណាកស្រុកដោយសារការចាំបាច់ ។ ដើម្បីសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ពួកគាត់យើងត្រូវប្រឹងប្រែងបន្ថែមទៀត ក្នុងការរក្សាភាពជាដៃគូ ការចែករំលែក និងការទទួលខុសត្រូវយ៉ាងពិតប្រាកដ ដើម្បីទទួលបានផលប្រយោជន៍ និងគោលដៅរួមទាំងអស់គ្នា។ ខ្ញុំសង្ឃឹមថាកិច្ចប្រជុំនេះនឹងទទួលបានលទ្ធផលល្អក្នុងកិច្ចការពារពលករទេសន្តរប្រវេសន៍ ដែលកំពុងធ្វើការនៅប្រទេសគោលដៅ ។

មតិចូលរួម និងចំណាប់អារម្មណ៍របស់គណៈប្រតិភូប្រទេសឡាវ ដោយ **លោកវរៈសេនីយ៍ឯក បណ្ឌិត ផេងសាវ៉ាញ់ ធីផាវង្សសៃ** (Pol.Col.Dr. Phengsavanh Thipphavongsay)

មតិចូលរួម និងចំណាប់អារម្មណ៍របស់គណៈប្រតិភូប្រទេសមីយ៉ាន់ម៉ា ដោយ ឯកឧត្តម ឧត្តមសេនីយ៍ឯក **អោង ធូ** (Aung Thu)អនុរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ នៃសហភាពមីយ៉ាន់ម៉ា។

សុន្ទរកថាបើក និងប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ។ សម្តេច បានមានប្រសាសន៍ថ្លែងអំណរគុណ ចំពោះការអញ្ជើញចូលរួមរបស់គណៈប្រតិភូទាំងពីរប្រទេស ឡាវ មីយ៉ាន់ម៉ា និងឯកឧត្តម លោកជំទាវ ភ្ញៀវជាតិអន្តរជាតិទាំងអស់ក្នុងកិច្ចប្រជុំពិគ្រោះយោបល់កម្រិតបច្ចេកទេសថ្នាក់មន្ត្រីជាន់ខ្ពស់ ស្តីពី **"តួនាទីប្រទេសបញ្ជូនក្នុងកិច្ចការពារពលករទេសន្តរប្រវេសន៍"** ។ **សម្តេចក្រឡាហោម** បានមានប្រសាសន៍បន្តថាៈ កិច្ចប្រជុំនេះ គឺផ្តោតលើកិច្ចពិភាក្សាគ្នាកុំឲ្យមានការភ័ន្តច្រឡំៈ

១.នេះគឺជាការជជែកគ្នាក្នុងន័យបច្ចេកទេស ព្រោះកិច្ចការខ្លះទាមទារឲ្យមានកិច្ចសហការគ្នារវាងប្រទេសទាំងបី យកទៅពិភាក្សាគ្នាដើម្បីការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ ដែលទៅតាមរយៈស្របច្បាប់ និងមិនស្របច្បាប់នៅប្រទេសគោលដៅនោះ។

២.ប្រទេសទាំងបីត្រូវជជែកគ្នាយកមតិដូចគ្នា ដែលជាគន្លឹះ នៃភាពប្រឈមផ្សេងៗពាក់ព័ន្ធទៅនឹងពលករដែលធ្វើការងារនៅទីនោះ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ពួកគាត់។

៣.ក្រោយពីរកឃើញបញ្ហារួមគ្នាហើយ យើងត្រូវរៀបចំជួបពិភាក្សាពិគ្រោះយោបល់ ជាមួយមន្ត្រីកម្រិតបច្ចេកទេសរបស់ប្រទេសថៃ លើកជាបញ្ហាដែលជាការប្រឈមផ្សេងៗ សំណូមពរដល់ភាគីប្រទេសគោលដៅ ដើម្បីលើកកម្ពស់សិទ្ធិ និងផលប្រយោជន៍របស់ពលករ ព្រមទាំងរកគន្លឹះដោះស្រាយពីភាពរងគ្រោះដោយអំពើជួញដូរមនុស្សក្រោមរូបភាពផ្សេងៗ។

ក្រោយពីបានប្រកាសបើកកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ ដោយ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានថតរូបអនុស្សាវរីយ៍រវាងគណៈប្រតិភូទាំងពីរប្រទេស និងភ្ញៀវជាតិ អន្តរជាតិដែលបានអញ្ជើញចូលរួម។

**ថ្ងៃទី១៖** ថ្ងៃពុធ ទី៣០ ខែតុលា ឆ្នាំ២០១៩

បន្ទាប់មក កិច្ចប្រជុំពិគ្រោះយោបល់លើកទី២ ត្រូវបានដំណើរការក្នុងកម្មវិធីដែលបានគ្រោងទុក និងមានការឯកភាពគ្នា និងអនុម័តលើរបៀបវារៈ រវាងភាគី នៃប្រទេសទាំងបី។

ក្រោយពិធីបើកបានបញ្ចប់កិច្ចប្រជុំពិគ្រោះយោបល់ បច្ចេកទេសកម្រិតថ្នាក់ដឹកនាំ លើកទី២ ស្តីពីតួនាទីប្រទេសបញ្ជូន ដើម្បីពង្រឹងកិច្ចការពារពលករទេសន្តរប្រវេសន៍បានចាប់ផ្តើមដំណើរការលើប្រធានបទៈ

**វគ្គទី១៖ កិច្ចពិភាក្សាអំពីច្បាប់ គោលនយោបាយ និងយន្តការដែលមានស្រាប់**

សម្របសម្រួលដោយ៖ Pol. Col. Kyaw Zaya Myanmar Police Force និងវាគ្មិនចូលរួមបកស្រាយលើប្រធានបទនេះមានចំនួន ៣រូប ។

**ក. ភាគីកម្ពុជា៖**

បកស្រាយដោយ៖ ឯកឧត្តម ហ៊ូ វុឌ្ឍី អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(វាគ្មិន)

១. ច្បាប់ គោលនយោបាយ និងយន្តការ

- មានយន្តការអនុវត្តការងារអន្តរក្រសួង ស្ថាប័នដូចជា ក្រសួងការងារ(មន្ទីរ) ក្រសួងការបរទេស(ស្ថានទូត) ក្រសួងមហាផ្ទៃ(អាជ្ញាធរមូលដ្ឋាន) ក្រុមការងារទេសន្តរប្រវេសន៍(គ.ជ.ប.ជ) ក្រុមការងារបច្ចេកទេសអនុវត្ត MOU ជាមួយប្រទេសថៃ និងទីភ្នាក់ងារជ្រើសរើសឯកជន
- អនុក្រឹត្យលេខ១៩០ ស្តីពី ការគ្រប់គ្រងទីភ្នាក់ងារឯកជន និងសេចក្តីប្រកាសណែនាំឲ្យអនុវត្តចំនួន ៨
- គោលនយោបាយទេសន្តរប្រវេសន៍ការងារ (២០១១) និងផែនការអនុវត្ត (២០១៩ ២០២៣) ដែលជាផ្នែកសំខាន់ នៃគោលនយោបាយមុខរបរ (២០២០ ២០២៥)
- កម្មវិធីការងារសមរម្យ អនុវត្តបាន ៤ដំណាក់កាលហើយ និងអនុវត្តបន្ត (២០១៩ ២០២៣)
- ផែនការយុទ្ធសាស្ត្រ (២០១៩ ២០២៣)
- ក្របខណ្ឌកិច្ចសហប្រតិបត្តិការមានដៃគូសំខាន់ៗ រដ្ឋាភិបាល នៃប្រទេសទទួលពលករនានា ដែលបានបង្កើតជា MOU ចំនួន ១៦ឯកសារ
- បច្ចុប្បន្នមាន MOU ជាមួយប្រទេសថៃ ចំនួន ៣៖ សហការការងារ ការប្រើប្រាស់កម្លាំងពលកម្ម និងការលុបបំបាត់ការជួញដូរមនុស្ស
- យកលិខិតុបករណ៍អន្តរជាតិជាត្រីវិស័យ ដែលមានអនុសញ្ញាអន្តរជាតិ ក្នុងការការពារពលករ និងគ្រួសាររបស់ពួកគាត់
- កិច្ចសហប្រតិការអាស៊ាន ការពារលើកកម្ពស់សិទ្ធិពលករ
- បញ្ជូនទីប្រឹក្សាការងារទៅប្រទេសទទួល ដើម្បីជួយការងារស្ថានទូត
- មានយន្តការដោះស្រាយវិវាទក្នុងទេសន្តរប្រវេសន៍

- មានសមត្ថកិច្ចចុះពិនិត្យទីភ្នាក់ងារជ្រើសរើសឯកជន
- មានការបណ្តុះបណ្តាលតម្រង់ទិសមុនចាកចេញ

២. បទពិសោធន៍ និងបញ្ហាប្រឈម

- ពលករមានការយល់ដឹងតិចអំពីទេសន្តរប្រវេសន៍ការងារ ពេលខ្លះដឹងដែរតែដោយសារភាពក្រីក្រទើបធ្វើឲ្យពួកគាត់ជួបបញ្ហា
- ពលករលើទូកនេសាទថៃមានភាពស្មុគស្មាញ ដោយការដោះស្រាយមិនទាន់ពេលវេលា
- សមត្ថភាពទីភ្នាក់ងារជ្រើសរើសឯកជនត្រូវការពង្រឹង (សរុបចំនួន ១២០ជាង) ដែលភ្នាក់ងារចាស់ៗមានលក្ខណៈល្អប្រសើរ តែភ្នាក់ងារថ្មីៗត្រូវការបណ្តុះបណ្តាលបន្ថែម
- សមត្ថភាពក្នុងការគ្រប់គ្រងទិន្នន័យពលករទើបតែចាប់ផ្តើម
- ការក្លែងឯកសារ Border pass ឬPassport ត្រូវថៃចាប់ (រកឃើញថាមិនក្លែងក្នុងកម្ពុជាទេ)
- ការចាប់បញ្ជូនត្រឡប់មកពីប្រទេសថៃ ដោយសារគ្មានឯកសារ ដែលខ្លះទៅតាមមេខ្យល់ ឬបងប្អូន មិត្តភក្តិ
- ការប្តូរឈ្មោះកាន់ seaman book លើទូកនេសាទថៃ
- ជនរងគ្រោះមិនសហការក្នុងការស្រាវជ្រាវរកមេខ្យល់

៣. ដំណោះស្រាយ

- ផ្តល់សេវារហ័ស ទាន់ចិត្ត មិនច្រើនដំណាក់កាល
- ពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករ
- ការអនុវត្តទេសន្តរប្រវេសន៍ការងាឲ្យកាន់តែមានប្រសិទ្ធភាព
- ចុះពិនិត្យទីភ្នាក់ងារជ្រើសរើសឯកជនទៀងទាត់
- ពង្រឹងសមត្ថភាពការបណ្តុះបណ្តាលតម្រង់ទិសមុនចាកចេញ
- បានដោះស្រាយជូនរាល់បណ្តឹងរបស់ពលករ
- ពង្រឹងការលើកកម្ពស់សមត្ថភាពទីភ្នាក់ងារឯកជន
- ពង្រឹងយន្តការដោះស្រាយវិវាទពលករ
- បន្តកិច្ចសហប្រតិបត្តិការទ្វេភាគី និងថ្នាក់តំបន់នានា ដើម្បីដកបទពិសោធន៍ក្នុងការពង្រឹងកិច្ចការពារពលករទេសន្តរប្រវេសន៍
- អ្នកគ្មានឯកសារឆ្លងកាត់ព្រំដែនត្រូវបាននគរបាលឃាត់ បានធ្វើការអប់រំ និងឲ្យធ្វើឯកសារស្របច្បាប់ឲ្យបានគ្រប់គ្រាន់ ត្រឹមត្រូវ។

## ខ. ភាគីឡាវ

បកស្រាយដោយៈ Mr.Phouttapho Aitthiphonh Technical Office of Employment Promotion Division, Department of Skill Development and Employment. (វាគ្មិន)

១. ច្បាប់ គោលនយោបាយ និងយន្តការ

- ប្រទេសឡាវមានចំនួនប្រជាជន ៦.៩លាននាក់ មានកម្លាំងពលកម្ម ១.៩លាននាក់ អត្រាគ្មានការងារ ៩.៤ ភាគរយ
- យុទ្ធសាស្ត្រអភិវឌ្ឍន៍ការងារ (២០១៦ ២០២៥) និងផែនការអនុវត្ត (២០១៦ ២០២០)
- ច្បាប់ការងារ

- អនុក្រឹត្យរបស់រដ្ឋាភិបាល ស្តីពី ការបញ្ជូនពលករឡាវទៅធ្វើការនៅក្រៅប្រទេស
- សេចក្តីណែនាំរបស់ក្រសួងការងារ លើការអនុវត្តអនុក្រឹត្យ ស្តីពី ការបញ្ជូនពលករឡាវទៅធ្វើការនៅក្រៅប្រទេស
- បទបញ្ញត្តិរបស់ក្រសួងការងារ ស្តីពី ការបង្កើត និងគ្រប់គ្រងភ្នាក់ងារជ្រើសរើស
- MOU ជាមួយប្រទេសថៃ ស្តីពី កំលាំងពលកម្ម (២០១៦)
- កិច្ចព្រមព្រៀងជាមួយប្រទេសថៃ ស្តីពី ការងារ (២០១៧)
- MOU ការបញ្ជូនពលករឡាវទៅធ្វើការនៅប្រទេសកូរ៉េ (២០១៦)
- MOU ការបញ្ជូនពលករឡាវទៅធ្វើការនៅប្រទេសជប៉ុន (២០១៧)

**យន្តការៈ**

- បង្កើតមណ្ឌលផ្តល់សេវាពលករ នៅទីក្រុងវៀងច័ន្ទ សម្រាប់សម្របសម្រួលពលករទៅក្រៅប្រទេស
- បង្កើតមណ្ឌលការងារចំនួន ១៤ នៅតាមខេត្តចំនួន ១៤ សម្រាប់ផ្តល់ព័ត៌មាន និងប្រឹក្សា
- បង្កើតភ្នាក់ងារជ្រើសរើសចំនួន ៣៥ កន្លែង
- អភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាលមុនចាកចេញ និងបណ្តុះបណ្តាលភ្នាក់ជ្រើសរើស
- តាមដានត្រួតពិនិត្យពលករដោយភ្នាក់ងារជ្រើសរើសនៅប្រទេសគោលដៅ
- វាយតម្លៃការអនុវត្តរបស់ភ្នាក់ងារជ្រើសរើស
- Labor attaché ដើម្បីសង្គ្រោះពលករ និងជាជំនួយពេលមានបញ្ហា
- បណ្តុះបណ្តាលគ្រូបង្គោលជួយជនរងគ្រោះនៅតាមបណ្តាខេត្ត

**២. បទពិសោធន៍ និងបញ្ហាប្រឈម**

- ពលករចំណាកស្រុកជាច្រើននៅមានកង្វះព័ត៌មានស្តីពីការធ្វើទេសន្តរប្រវេសន៍ស្របច្បាប់ និងដោយសារចំនួនមេខ្យល់ខុសច្បាប់ច្រើនបាននាំឲ្យមានការចំណាយខ្ពស់
- ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅមានដែនកំណត់ ដែលនាំឲ្យមានការធ្វើទេសន្តរប្រវេសន៍មិនច្បាស់លាស់
- ការផ្តល់ឯកសារមិនគ្រប់គ្រាន់ និងមិនមានការកំណត់ភេទ ដែលនាំឲ្យមានការពិបាកក្នុងការដោះស្រាយបញ្ហាបន្ទាន់
- បញ្ហាក្នុងការបញ្ជាក់អត្តសញ្ញាណពលករឡាវ (៣៧២៨៨/៧១០០០ នាក់ = ៥៧%)
- ពលករឡាវដែលគ្មានឯកសារត្រូវបានធ្វើឲ្យស្របច្បាប់នៅប្រទេសថៃចំនួន៣០៣០៩ (២០១៧ ២០១៨)
- មានច្រើនដំណាក់កាល ចំណាយខ្ពស់ និងប្រើពេលយូរ
- មេខ្យល់ខុសច្បាប់ទទួលបានប្រយោជន៍ខ្ពស់
- ពលករខុសច្បាប់មិនអាចបង្ហាញឲ្យដឹងទៅតាមចំនួនប្រកាស ដោយសារត្រូវចំណាយថ្លៃសេវាបន្ថែម
- ពលករនៅតែត្រូវបានផាកពិន័យដោយសារតែកង្វះខាតការផ្សព្វផ្សាយព័ត៌មាន

**៣. ដំណោះស្រាយ**

- ពង្រឹងការអនុវត្តច្បាប់ និងបទបញ្ញត្តិ ដើម្បីសម្រួលដល់ពលករទេសន្តរប្រវេសន៍នៅក្នុងប្រព័ន្ធ MOU
- ជំរុញ និងសម្របសម្រួលការផ្សព្វផ្សាយព័ត៌មានទូទាំងប្រទេស ដើម្បីកាត់បន្ថយទេសន្តរប្រវេសន៍ខុសច្បាប់
- វិនិយោគបន្ថែមទៅលើកម្មវិធីសមាហរណកម្ម
- ផ្សព្វផ្សាយច្បាប់ការងារថ្មីដល់អាជ្ញាធរ និងសង្គម
- កែលម្អ និងពង្រីកមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈទូទាំងប្រទេស
- ពង្រឹងសមត្ថភាពមណ្ឌលសេវាកម្មការងារ និងគណៈកម្មការទន្លេមេគង្គ

- លើកកម្ពស់ការអភិវឌ្ឍជំនាញ បរិមាណ និងគុណភាព
- អភិវឌ្ឍគុណភាព និងស្តង់ដានៃប្រព័ន្ធ LMI
- លើកកម្ពស់ការសម្របសម្រួល និងកិច្ចសហការរវាងដៃគូទ្វេភាគី ត្រីភាគី និងភ្នាក់ងារជ្រើសរើស ដើម្បីការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍

## គ. ភាគីមីយ៉ាន់ម៉ា

បកស្រាយដោយ៖ Ms. Aye Aye Moe, Director, Ministry of labor, Immigration and Population.(វាគ្មិន)

១. ច្បាប់ គោលនយោបាយ និងយន្តការ

- ប្រទេស មីយ៉ាន់ម៉ា មានចំនួនប្រជាជន ៥៣ លាននាក់
- មានគោលនយោបាយគ្រប់គ្រងពលករទេសន្តរប្រវេសន៍
- អនុម័តគោលនយោបាយការងារក្រៅប្រទេស (១៩៩០)
- បង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០១១)
- បង្កើតភ្នាក់ងារជ្រើសរើសក្រៅប្រទេស (២០១៣)
- ផែនការសកម្មភាពពលករទេសន្តរប្រវេសន៍ (២០១៤-២០១៨) និងលើកទី២ (២០១៨-២០២២)
- ក្រសួងការងារបានកំណត់ច្បាប់សម្រាប់ទីភ្នាក់ងារជ្រើសរើស
- បានបញ្ជូនពលករ ៨០០.០០០នាក់ តាមរយៈទីភ្នាក់ងារ (កូរ៉េ ម៉ាឡេស៊ី ថៃ សឹង្ហបុរី)
- បានបណ្តុះបណ្តាលតម្រង់ទិសពលករមុនចាកចេញ ដោយឥតគិតថ្លៃ
- ស្ថានទូតជាអ្នកផ្តល់ព័ត៌មានពេលពលករមានបញ្ហា
- ផ្តល់ព័ត៌មានអំពីលក្ខខណ្ឌការងារ មុននឹងចុះហត្ថលេខាឯកភាពចេញទៅធ្វើការ
- មន្ត្រីពាក់ព័ន្ធ និងមន្ត្រីអន្តោប្រវេសន៍ ធ្វើបទបង្ហាញដល់ពលករមុនចាកចេញ
- មានMOU ជាមួយ ថៃ កូរ៉េ ជប៉ុន សឹង្ហបុរី
- ពលករដែលត្រូវចាប់ខ្លួននៅប្រទេសថៃ ត្រូវបញ្ជូនមកវិញតាមនីតិវិធីប្រទេសនិងប្រទេស
- មានកិច្ចសហការក្នុងប្រទេស ក្នុងការផ្តល់ជំនួយដល់ពលករអំពីដំណើរការការពារ
- មានកិច្ចសហការជាមួយអង្គការ IOM, UN-Women ....
- មានយន្តការដោះស្រាយបណ្តឹង សេវា ២៤ម៉ោង/២៤ ៧ថ្ងៃ/៧ តាំងពីឆ្នាំ២០១៣ ដែលទទួលបណ្តឹងប្រមាណ ២៩០០ បណ្តឹង

២. បទពិសោធន៍ និងបញ្ហាប្រឈម

- ការផ្សព្វផ្សាយអំពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាពនៅមិនទាន់បានល្អ
- ការចាកចេញដោយខុសច្បាប់នៅតែមាន
- ខ្វះការគាំពារ ការលើកកម្ពស់កម្មវិធី ណែនាំភ្នាក់ងារជ្រើសរើស និយោជិត និងនិយោជក
- ពលករមិនសូវយល់ដឹងអំពីទេសន្តរប្រវេសន៍ការងារ
- ពលករទៅប្រទេសជិតខាងមិនទទួលបានប្រាក់ឈ្នួល ដោយពួកខិលខូចកេងប្រវ័ញ្ច
- ពលករត្រូវបានដកហូតលិខិតឆ្លងដែន

៣. ដំណោះស្រាយ

- ពលករមិនសូវយល់ដឹងអំពីទេសន្តរប្រវេសន៍ការងារ តែក៏ទទួលបានការគាំពារសង្គមនៅប្រទេសទទួល

- ក្រសួងការងារ ផ្តល់សេវាសន្តិសុខសង្គម សុវត្ថិភាពការងារ និងទំនាក់ទំនងព័ត៌មាន
- ពង្រឹងពលករក្នុងការ ពិនិត្យព័ត៌មាន និងយល់ច្បាស់អំពីលក្ខខណ្ឌការងារ
- មានយន្តការដោះស្រាយជាមួយប្រទេសថៃទ្វេភាគី
- ពលករមួយចំនួនត្រូវបានកេងប្រវ័ញ្ចដោយក្រុមសង្គមងងឹត និងឈ្មួញកណ្តាលនៅក្រៅប្រទេស ដែលករណីត្រូវដោះស្រាយដោយប៉ូលីស
- បច្ចុប្បន្ន មានរចនាសម្ព័ន្ធពលករចូលប្រទេសថៃច្រើន
- មានយន្តការសហប្រតិបត្តិការរវាងប៉ូលីសនៅព្រំដែន បើមានបញ្ហាគឺដោះស្រាយដោយប្រជុំទ្វេភាគី ដោយព្យាយាមពិភាក្សាការងារ
- មានយន្តការកិច្ចប្រជុំអន្តរក្រសួង
- ពលករត្រូវបានដកហូតលិខិតឆ្លងដែន ត្រូវរាយការណ៍ទៅប៉ូលីសនៅប្រទេសទទួល និងព្យាយាមតាមការទូត ហើយបើមានបញ្ហាធំគឺត្រូវប្រើជំនួយផ្នែកច្បាប់ (MCA)
- មាន SOMTC មានក្រុមការងារប្រឆាំងការជួញដូរមនុស្ស ដែលអាចរំលែកព័ត៌មាននៅលើតុ
- កិច្ចសហប្រតិបត្តិការ យន្តការពិគ្រោះយោបល់ គឺជាការអនុវត្តល្អ

**វគ្គទី២៖ អំពីបទពិសោធ និងភាពប្រឈម**

សម្របសម្រួលដោយ៖ លោកជំទាវ ហ៊ូ សាមិត្ត រដ្ឋលេខាធិការ ក្រសួង កិច្ចការនារី

វាគ្មិនចូលរួមបកស្រាយលើប្រធានបទនេះមានចំនួន ៣រូប

**ក.ភាគីឡាវ**

បកស្រាយដោយ៖ Mr.Phouttapho Aitthiphonh Technical Office of Employment Promotion Division, Department of Skill Development and Employment. (វាគ្មិន)

- ប្រជាពលរដ្ឋឡាវចេញទៅធ្វើការនៅក្រៅប្រទេសមានចំនួនច្រើន
- ពាក្យសុំចេញទៅធ្វើការនៅក្រៅប្រទេស (ក្រសួងការងារ ផ្តល់ជូនលើគ្រប់វិស័យ)
- ភាគរយពលករចេញទៅធ្វើការនៅក្រៅប្រទេសទៅតាមវិស័យ
- ៩០ ភាគរយ មិនមានការអប់រំខ្ពស់
- ពលករទេសន្តប្រវេសន៍មានការកើនឡើង
- មានការចុះបញ្ជីគ្រប់គ្រង
- គម្លាតពលករខុសច្បាប់កំពុងមានបញ្ហា

**ខ.ភាគីមីយ៉ាន់ម៉ា**

បកស្រាយដោយ៖ Pol. Col. Kyaw Zaya Myanmar Police Force (វាគ្មិន)

- មានការអនុវត្តច្បាប់ទាក់ទង និងការជួញដូរមនុស្ស
- មានយន្តការប្រជុំអន្តរក្រសួង (អាស៊ាន)
- មាន MOU បញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស
- បានជួបពិភាក្សាគ្នា រវាងខេត្តជាប់ព្រំដែននៃប្រទេស
- ដំណោះស្រាយដែលមានបញ្ហា ធ្វើឡើងតាមការទូត
- មានសេនានុព័ន្ធការងារប្រចាំនៅប្រទេសគោលដៅ
- ការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសតាមរយៈ MOU
- មានការសហការគ្នា រវាងនគរបាលព្រំដែន (កិច្ចប្រជុំទ្វេភាគី)

- ជម្រុញការអនុវត្តន៍យន្តការនានា ដើម្បីធ្វើការឆ្លើយតប
- អនុវត្តផែនការសកម្មភាពជាមួយអង្គការដៃគូ

**គ.ភាគីកម្ពុជា**

បកស្រាយដោយ៖ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន(វាគ្មិន)

បានលើកឡើងពីស្ថានភាពភូមិសាស្ត្រព្រំដែន ច្រកទ្វារ និងលំហូរពលករ(ចេញ-ចូល)

- ពលករសុំចូលទៅធ្វើការ និងវិលត្រលប់មកវិញនៅពេលល្ងាច
- ធ្វើប័ណ្ណចេញចូល រយៈពេលខ្លី និងវែង
- ការប្រើប្រាស់ប័ណ្ណចេញចូលរបស់ពលករខ្លះ ត្រូវបានពលករខ្លះមិនប្រើប្រាស់
- ពលករខ្លះទៅធ្វើការពេលព្រឹកហើយត្រលប់មកវិញនៅពេលល្ងាច និង ពលករខ្លះទៀតមិនធ្វើដំណើរវិលត្រលប់មកវិញ ។
- ពលករលើវិស័យនេសាទក្នុងចំណោម ១៧រូប មាន៣រូប ជាពលករកម្ពុជា ត្រូវបានរកឃើញជារឿងវិវាទការងារទៅវិញ ។
- ពលករត្រូវបានគេប្តូរអត្តសញ្ញាណ
- ពលករចូលទៅក្នុងប្រទេសថៃដែលត្រូវបានអាជ្ញាធរថៃចាប់ខ្លួន គឺតាមរយៈមេខ្យល់ ។
- ពលករគ្មានឯកសារគ្រប់គ្រាន់

បន្ទាប់ពីវាគ្មិន នៃប្រទេសទាំងបី បានធ្វើការបកស្រាយពាក់ព័ន្ធនឹងប្រធានបទខាងលើ ក៏មានចោទជាសំនួរទៅខាងភាគីឡាវ និងមីយ៉ាន់ម៉ា ពីតំណាងក្រសួង និងអង្គការដៃគូមួយចំនួនដូចខាងក្រោម៖

-លោក **លឹម ទិត្យ** តំណាងអង្គការ UN-Women តើយើងត្រូវរកមធ្យោបាយបែបណាដើម្បីការពារពលករ និងទិន្នន័យពលករចេញ-ចូល និងពលករដែលមាន កូនចៅកំពុងរស់នៅជាមួយ ?

-លោក **សេក សារឿន តំណាងអង្គការ IJM** តើយើងត្រូវធ្វើដូចម្តេចចំពោះពលករ មីយ៉ាន់ម៉ា ដែលកំពុងធ្វើការ ងារលើទូកនេសាទបានជួបនូវបញ្ហា ? (មានសំណុំរឿងជនរងគ្រោះលើទូកនេសាទ)

-លោក **អ៊ុក រ៉ាវុធ អនុប្រធាននាយកដ្ឋាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** តើពលករឡាវ និងមីយ៉ាន់ម៉ា បានជួបនូវបញ្ហាដូចកម្ពុជាដែរឬទេ? ព្រោះថៃបានបន្តសុពលភាពឲ្យពលករដោយគ្រាន់តែផ្តល់ព័ត៌មានមកតែប៉ុណ្ណោះ។

ជាការឆ្លើយតបនឹងសំនួរខាងលើ ភាគីទាំងពីរ (ឡាវ-មីយ៉ាន់ម៉ា) បានធ្វើការបកស្រាយ៖

**ចម្លើយ៖ ភាគីមីយ៉ាន់ម៉ា**

- កិច្ចសហប្រតិបត្តិការ គឺផ្អែកទៅលើច្បាប់ជាតិ និកិច្ចសហការជំនួយផ្នែកច្បាប់ទៅវិញទៅមក។
- ពលកររងគ្រោះទូកនេសាទគេបានមកជួបតំណាងស្ថានទូត ដើម្បីរកឯកសាររបស់ពួកគេ និង ការពាក់ព័ន្ធផ្សេងៗ ។
- ថៃមិនផ្តល់ពត៌មាន ទាក់ទង និងការបន្តផ្តល់ការងារចំពោះពលករ ។

**ចម្លើយ៖ ភាគីឡាវ**

- មិនធ្លាប់ជួបប្រទះនៅបញ្ហាដូចកម្ពុជាទេព្រោះ
- មានចុះអនុស្សរណៈជាមួយគ្នា(ឡាវ-ថៃ)
- មានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- មានទីភ្នាក់ងារជ្រើសរើស

- មានគណៈកម្មាធិការជាតិទន្លេមេគង្គ
- ស្នើសុំទៅភាគីថៃចំពោះពលករមិនស្របច្បាប់ ធ្វើឲ្យមានភាពស្របច្បាប់វិញ

**វគ្គទី៣៖** ដឹកនាំសម្របសម្រួលដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

*លោកជំទាវ* បានលើកឡើងអំពីគន្លឹះ នៃបញ្ហាប្រឈម/ បញ្ហាប្រឈមសំខាន់ៗដែលកំពុងជួបប្រទះ និងដំណោះស្រាយសមស្រប។ លោកជំទាវ មានប្រសាសន៍ថា យើងទទួលស្គាល់ចំពោះដំណោះស្រាយបញ្ហា គឺជាភារកិច្ចរបស់ប្រទេសនីមួយៗ តែសម្រាប់ប្រទេសទាំងបី កម្ពុជា ឡាវ មីយ៉ាន់ម៉ា ជាប្រទេសបញ្ជូន ត្រូវតែធ្វើការដោះស្រាយបញ្ហារួមគ្នាជាមួយប្រទេសគោលដៅ(ប្រទេសទទួល) ដូចជា៖

- បញ្ហារបស់ពលករធ្វើការលើទូកនេសាទ
- នីតិវិធីដើម្បីការពារពលករនៅទីនោះ
- ការបញ្ជូនត្រឡប់មកវិញ ដោយពួកគាត់បាត់បង់សមត្ថភាពពលកម្ម
- បញ្ហាកុមារដែលទៅតាម ឳពុក ម្តាយ ធ្វើការនៅទីនោះ
- បញ្ហាពលករដែលកាន់ឯកសារហួសសុពលភាព និងមិនមានឯកសារគ្រប់គ្រាន់
- វិធានការក្នុងការទប់ស្កាត់

**ភាគីឡាវ៖**

- ក្រសួងការងារ និងសមត្ថកិច្ច បានធ្វើការងារនេះជាមួយភាគីថៃ
- មិនមានទិន្នន័យពលករកាន់ឯកសារមិនត្រឹមត្រូវ ឬហួសសុភលភាពទេ
- ធ្លាប់ផ្តល់ជូនឯកសារស្របច្បាប់ជាមួយភាគីថៃដល់ពលករបានជាងបីម៉ឺននាក់
- ពលករដែលចេញទៅធ្វើការនៅក្រៅប្រទេស គឺមានឯកសារគ្រប់គ្រាន់
- សព្វថ្ងៃមានពលករកំពុងធ្វើការក្នុងប្រទេសថៃ មានជាងម្ភៃម៉ឺននាក់
- មិនមានពលករធ្វើការលើទូកនេសាទទេ

**ភាគីមីយ៉ាន់ម៉ា៖**

- សុពលភាពការងារនៅក្រៅប្រទេសរបស់ពលករ មានរយៈពេលតែ ២ឆ្នាំ
- ពេលហួសសុពលភាពពលករត្រូវតែត្រឡប់មកបំពេញឯកសារឡើងវិញ
- ពលករអាចចេញទៅធ្វើការនៅក្រៅប្រទេសរយៈពេល ៤ឆ្នាំ
- ពុំមានពលករដែលគ្មានឯកសារចេញទៅធ្វើការនៅក្រៅប្រទេសទេ
- មានទីភ្នាក់ងារជ្រើសរើសពលករ ដែលទទួលខុសត្រូវលើបញ្ហានេះ
- មិនមានពលករធ្វើការលើទូកនេសាទទេ
- ពេលពលករមានបញ្ហា ពួកគាត់អាចទៅជួបទូតដើម្បីជួបចរចាដោះស្រាយជាមួយប្រទេសគោលដៅ

**<u>ថ្ងៃទី២៖</u> ថ្ងៃព្រហស្បតិ៍ ទី៣១ ខែតុលា ឆ្នាំ២០១៩ (បិទកម្មវិធី)**

- ពិនិត្យ និងពិភាក្សាលើកំណត់ហេតុរួមគ្នាដើម្បីចុះហត្ថលេខារួមគ្នា
- ចុះហត្ថលេខារួមគ្នាលើកំណត់ហេតុ
- ចំណាប់អារម្មណ៍របស់តំណាងដែលបានចូលរួម ដើម្បីបិទកម្មវិធី

**លោក ហេង សុជាតិ តំណាងអង្គការ UN-Women** ប្រចាំកម្ពុជាមានសេចក្តីសប្បាយរីករាយ និងកិត្តិយសណាស់ ដែលមានឱកាសចូលរួមក្នុងកម្មវិធីបិទកិច្ចប្រជុំនាពេលនេះ។ សូមថ្លែងអំណរគុណដល់ គ.ជ.ប.ជ ដែលបាន

រៀបចំព្រឹត្តការណ៍ដ៏សំខាន់នេះ និងវត្តមានដ៏ថ្លៃថ្លារបស់ គណៈប្រតិភូនៃប្រទេសទាំងបី (កម្ពុជា ឡាវ ភូមា) និងភ្ញៀវកិត្តិយសដែលបានអញ្ជើញចូលរួមទាំងអស់។ UN-Women គិតថាកិច្ចប្រជុំនេះគឺពិតជាចំណុចសំខាន់ក្នុងការចែករំលែកគំនិត ការយល់ដឹង និងបទពិសោធន៍សម្រាប់ប្រទេសបញ្ជូនទាំងបី ក្នុងកិច្ចប្រឹងប្រែងបង្កើនការការពារពលករទេសន្តរប្រវេសន៍ ជាពិសេសពលករជាស្ត្រី។ សូមកោតសរសើរចំពោះការប្តេជ្ញាចិត្តចំពោះកិច្ចប្រជុំនេះដែលនាំមកនូវលទ្ធផលវិជ្ជមាន និងឯកភាពគ្នាចុះហត្ថលេខាលើកំណត់ហេតុ ដើម្បីធ្វើសកម្មភាពបន្តទៀត ។ សង្ឃឹមថា អ្នកទាំងអស់គ្នានឹងយកស្មារតី និងលទ្ធផលនៃកិច្ចប្រជុំប្រទេសបញ្ជូននេះ បង្កើតជាសកម្មភាពក្នុងការជំរុញ ការការពារពលករទេសន្តរប្រវេសន៍ ជាពិសេសពលករជាស្ត្រី។

គណៈប្រតិភូឡាវ ដោយលោក វរៈសេនីយ៍ឯក បណ្ឌិត **ផេងសាវ៉ាញ់ ធីផាវង្សសៃ** (Pol.Col.Dr. Phengsavanh Thipphavongsay) អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាល និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស ក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋ ប្រជាមានិតឡាវៈ សូមថ្លែងនូវសេចក្តីសោមនស្សរីករាយ ដែលបានមកចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ថ្នាក់មន្ត្រីជាន់ខ្ពស់កម្រិតបច្ចេកទេស ស្តីពី ប្រទេសបញ្ជូនក្នុង **កិច្ចការពារពលករទេសន្តរប្រវេសន៍** នៅលើទឹកដីខេត្តសៀមរាប ប្រទេសកម្ពុជា។ សង្កេតឃើញថា ប្រទេសយើងទាំងបីមានសណ្ឋានប្រហាក់ប្រហែលគ្នា ទាំងប្រពៃណី ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងមានព្រំប្រទល់ជាប់ជាមួយប្រទេសថៃដូចគ្នា។ សង្ឃឹមថា កិច្ចប្រជុំលើកនេះនឹងអាចអាចស្វែងរកបញ្ហាប្រឈម ក៏ដូចជាដំណោះស្រាយរួមគ្នា មួយទាក់ទងនឹងកិច្ចការពារពលករទេសន្តរប្រវេសន៍ ដើម្បីការពារសិទ្ធិការគាំពារ ការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ម្យ៉ាងវិញ គឺយើងបានធ្វើការផ្លាស់ប្តូរ បទពិសោធន៍ល្អៗជាមួយគ្នាទៅវិញទៅមកទាក់ទងនឹងការងារនេះ។ ក្រោយពីបានប្រជុំពិគ្រោះយោបល់ ស្វែងរកបញ្ហាប្រឈម និងដំណោះស្រាយ លើកិច្ចការពារពលករទេសន្តរប្រវេសន៍ យើងក៏បានធ្វើកំណត់ហេតុ និងព្រមព្រៀងចុះហត្ថលេខាលើកំណត់ហេតុនេះដោយយល់ស្របតាមខ្លឹមសារ អត្ថន័យទាំងអស់ នៃកំណត់ហេតុ យើងនឹងខិតខំប្រឹងប្រែងអនុវត្តតាមខ្លឹមសារនេះ។ ក្នុងនាមប្រធានគណៈប្រតិភូប្រទេសឡាវ សូមថ្លែងអំណរគុណ ចំពោះភាគីកម្ពុជា និងភាគីមីយ៉ាន់ម៉ាដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមក្នុងកិច្ចប្រជុំនាឱកាសនេះ និងខំប្រឹងប្រែងលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ជូនពលករទេសន្តរប្រវេសន៍ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

គណៈប្រតិភូមីយ៉ាន់ម៉ា ដឹកនាំដោយ **ឯកឧត្តម ឧត្តមសេនីយ៍ឯក អោង ធូ** (Aung Thu) អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃសហភាពមីយ៉ាន់ម៉ា អញ្ជើញឡើងមានចំណាប់អារម្មណ៍បិទកិច្ចប្រជុំថាៈ មានសេចក្តីរីករាយដែលប្រទេសយើងទាំងបីបានរួមគ្នាប្រជុំពិគ្រោះយោបល់ស្តីពី ប្រទេសបញ្ជូនក្នុង **កិច្ចការពារពលករទេសន្តរប្រវេសន៍** ទាក់ទងយន្តការ គោលនយោបាយ ការគាំពារ ការផ្លាស់ប្តូរបទពិសោធន៍ការងារ យើងទទួលបានចំណេះដឹងល្អៗក្នុងការស្វែងរកបញ្ហាប្រឈម និងដំណោះស្រាយជូនពលករទេសន្តរប្រវេសន៍ដែលកំពុងធ្វើការ និងរស់នៅក្នុងប្រទេសគោលដៅ។ យើងត្រូវរួមគ្នាលើកកម្ពស់សិទ្ធិពលករ និងផលប្រយោជន៍របស់ពលករ ហើយការងារដែលយើងចាំបាច់ចំបងគឺ ការគ្រប់គ្រងពលករ។ ចុងក្រោយសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលកម្ពុជា និងគណៈប្រតិភូប្រទេសឡាវ ដែលបានចំណាយពេលអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំនាពេលនេះ និងសូមថ្លែងអំណរគុណចំពោះបណ្តាអង្គការពាក់ព័ន្ធនានាដែលបានជួយសម្របសម្រួលតាំងពីដើមរហូតដល់ចប់។ ក្រោយពីយើងបានចុះហត្ថលេខាលើកំណត់ហេតុកិច្ចប្រជុំនេះរួចមក យើងនឹងអនុវត្តការងារនេះឲ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាព។

គណៈប្រតិភូកម្ពុជា ដឹកនាំដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជា**អនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ បានអញ្ជើញមានចំណាប់អារម្មណ៍ និងបិទកិច្ចប្រជុំពិគ្រោះយោបល់ថាៈ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ដែលជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពី ប្រទេសបញ្ជូនក្នុង កិច្ចការពារពលករ

ទេសន្តរប្រវេសន៍ សង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា អ្វីដែលយើងទាំងបីប្រទេសបានលើកឡើងដែលជាបញ្ហាប្រឈម ទោះបីមានលក្ខណៈដូចគ្នា និងមិនដូចគ្នាក្តី តែយើងបានសិក្សាស្រាវជ្រាវរកឃើញនូវបញ្ហាប្រឈមមួយចំនួន ក៏ដូចជាដំណោះស្រាយល្អៗ ក្នុងការការពារពលករទេសន្តរប្រវេសន៍ដែលកំពុងធ្វើការងារ និងរស់នៅក្នុងប្រទេសគោលដៅ ជាពិសេសពលករលើទូកនេសាទ។ ដូច្នេះយើងត្រូវរួមសហការគ្នា ដើម្បីកិច្ចការពារផលប្រយោជន៍ លោកម្ពស់សិទ្ធិរបស់ពលករយើង។ យើងនឹងមានពេលក្រោយទៀតក្នុងការជួបប្រជុំពិភាក្សាគ្នាលើកក្រោយទៀត ទាក់ទងនឹងបញ្ហាការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស យើងអាចប្រារព្ធធ្វើនៅប្រទេសណាមួយក៏បាន។ សង្ឃឹមថា បន្ទាប់ពីបានចុះហត្ថលេខាលើកំណត់ហេតុដែលបានពិនិត្យរួចលើខ្លឹមសារ អត្ថន័យរួចមក ប្រទេសយើងទាំងបីនឹងរួមសហការគ្នាល្អក្នុងការបង្ការ ទប់ស្កាត់បញ្ហាទាំងនេះ។ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** ធ្វើការថ្លែងអំណរគុណចំពោះគណៈប្រតិភូ នៃប្រទេសទាំងពីរ ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពី ប្រទេសបញ្ជូនក្នុង **កិច្ចការពារពលករទេសន្តរប្រវេសន៍** និងថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងមន្ត្រីគ្រប់ជាន់ថ្នាក់ ព្រមទាំងអង្គការដៃគូពាក់ព័ន្ធដែលបានជួយធ្វើការសម្របសម្រួលក្នុងការងារនេះតាំងពីដើមរហូតដល់បញ្ចប់កម្មវិធី។

សូមគោរពជូនពរ គណៈប្រតិភូទាំងពីរប្រទេស ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីគ្រប់ជាន់ថ្នាក់ ភ្ញៀវជាតិ អន្តរជាតិ ព្រមទាំងអង្គការដៃគូពាក់ព័ន្ធទាំងអស់ទទួលបានជោគជ័យគ្រប់ភារកិច្ច និងសុវត្ថិភាពគ្រប់ពេលវេលា។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ដប់ពីរ និងដប់ប្រាំនាទី ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំកុរ ឯស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ទោ ឱក_សង្សារ

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃសុក្រ ៤រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩

**អគ្គលេខាធិការរង**

ឧត្តមសេនីយ៍ឯក.យឹម_ធីរៈ

បានឃើញ

15/11/19

# សមាសភាពចូលរួមជាគណៈអធិបតី

## ពិធីបើក នៃកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ កម្រិតថ្នាក់ដឹកនាំបច្ចេកទេស នៃប្រទេសបញ្ជូនទាំងបី (កម្ពុជា ឡាវ មីយ៉ាន់ម៉ា) ស្តីពី តួនាទីប្រទេសបញ្ជូន ដើម្បីពង្រឹងកិច្ចការពារពលករទេសន្តរប្រវេសន៍

ថ្ងៃពុធ-ព្រហស្បតិ៍ ៣-៤កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ត្រូវនឹងថ្ងៃទី៣០-៣១ ខែតុលា ឆ្នាំ២០១៩ នៅសណ្ឋាគារសុខាល័យអង្គរ ខេត្តសៀមរាប

១.វ.ឯក បណ្ឌិត **ផេងសាវ៉ាញ់ ធីផាវុង្សៃ** (Pol.Col.Dr. Phengsavanh Thipphavongsay) អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាល និងជាប្រធានលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស ក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋ ប្រជាមានិតឡាវ និងមន្ត្រីបច្ចេកទេស ចំនួន ៥ រូប

២.ឯ.ឧ.ឯ **អោង ធូ** (Aung Thu) អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃសហភាពមីយ៉ាន់ម៉ា និងមន្ត្រីបច្ចេកទេស ចំនួន ៥ រូប

៣.**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងឯកឧត្តម លោកជំទាវ លោក លោកស្រី ជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ១៨ រូប ។

| | | |
|---|---|---|
| ៤.ឯកឧត្តម | ញឹក វណ្ណារ៉ា | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ៥.លោកជំទាវ | ហ៊ូ សាមិត្ត | រដ្ឋលេខាធិការក្រសួងកិច្ចការនារី |
| ៦.ឯកឧត្តម | ហ៊ូ វុឌ្ឍី | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៧.លោកជំទាវ | សឿ សុជាតា | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៨.ឯកឧត្តម | កែ ពិសិដ្ឋ | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ៩.ឯកឧត្តម | រឿន រិទ្ធីរ័ត្ន | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ១០.ល.នាយ | យក់ សុខា | អគ្គស្នងការរងនគរបាលជាតិ |
| ១១.ល.ឧ.ឯក | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការ គ.ជ.ប.ជ |
| ១២.ឯកឧត្តម | ប្រាក់ សុវណ្ណ | អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ |
| ១៣.ឯកឧត្តម | ផាន់ ចាន់ធុល | អភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន |
| ១៤.ល.ជំ | យូ សុភា | អភិបាលរង ខេត្តសៀមរាប |
| ១៥.ឯ.ឧ.ឯក | អ៊ុក ហៃសីឡា | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៦.ឯ. ឧ.ឯក | ខៀវ ចាន់រ៉ា | អគ្គលេខាធិការរង គ.ជ.ប.ជ |
| ១៧.ឯ.ឧ.ឯក | យឹម វិរៈ | អគ្គលេខាធិការរង គ.ជ.ប.ជ |
| ១៨.ឯ.ឧ.ឯក | យ៉ែម ច័ន្ទណារុំ | អគ្គលេខាធិការរង គ.ជ.ប.ជ |
| ១៩.ល.ឧ.ទោ | រ៉ែន សិរីលក្ខិណា | អគ្គលេខាធិការរង គ.ជ.ប.ជ |
| ២០.ឯ.ឧ.ឯក | ជីវ ផល្លី | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |

២១.តំណាងអង្គការដៃគូពាក់ព័ន្ធ
២២.ភ្ញៀវជាតិ អន្តរជាតិ
២៣.មន្ត្រីពាក់ព័ន្ធ នៃអគ្គលេខធិការដ្ឋន គ.ជ.ប.ជ និងមន្ទីរជុំវិញខេត្តសៀមរាប

**សរុបចំនួនៈ ៨២ រូប/ ស្រី ១៩ រូប**